# ព័ត៌មាននេះអាចជួយលោកអ្នក
# នៅពេលលោកអ្នកបោះឆ្នោត

**អ្វីខ្លះដែលត្រូវប្រាប់មន្ត្រីផ្លូវការផ្នែកបោះឆ្នោត។ សូមប្រាប់មន្ត្រីផ្លូវការនៅកន្លែងបោះឆ្នោតអំពីឈ្មោះទាំងអស់របស់លោកអ្នក (នាមត្រកូល និងនាមខ្លួន) និងអាសយដ្ឋាន។** មន្ត្រីផ្លូវការនឹងផែកមើលបញ្ជីបោះឆ្នោតដើម្បីឲ្យបានដឹងថាតើឈ្មោះរបស់លោកអ្នកមានចុះនៅក្នុងបញ្ជីនោះឬទេ មុននឹងលោកអ្នកអាចបោះឆ្នោតបាន។ ប្រសិនបើលោកអ្នកចង់ នោះលោកអ្នកអាចសរសេរឈ្មោះរបស់លោកអ្នក និងអាសយដ្ឋានពីលើក្រដាសមួយសន្លឹក រួចហើយប្រគល់ទៅឲ្យមន្ត្រីផ្លូវការនៅកន្លែងតុបោះឆ្នោត។

## សន្លឹកឆ្នោត

បន្ទាប់មកមន្ត្រីផ្លូវការនឹងប្រគល់ជូនលោកអ្នកនូវសន្លឹកឆ្នោតពីរ**(២)សន្លឹក។ សន្លឹកឆ្នោតតូចគឺសំរាប់សភានីតិបញ្ញត្តិ** (ដើម្បីបោះឆ្នោតជ្រើសរើសអ្នកតំណាងរាស្ត្រនៃតំបន់របស់លោកអ្នក) **និងសន្លឹកឆ្នោតធំគឺសំរាប់ក្រុមប្រឹក្សានីតិបញ្ញត្តិ** (សំរាប់បោះឆ្នោតជ្រើសរើសសមាជិក២១នាក់នៃក្រុមប្រឹក្សា)។

**សូមយកសន្លឹកឆ្នោតនោះទៅកាន់បន្ទប់បោះឆ្នោតដែលលោកអ្នកអាចបោះឆ្នោតដោយគ្មាននរណាឃើញ។**

## ការបោះឆ្នោតសំរាប់សភានីតិបញ្ញត្តិ (សន្លឹកឆ្នោតតូច)

លោកអ្នកត្រូវគូសលើសន្លឹកឆ្នោតដោយដាក់លេខ “1” នៅក្នុងគំនូស៤ជ្រុង ទល់មុខនឹងឈ្មោះបេក្ខជនដែលលោកអ្នកប្រាថ្នាចង់បោះឆ្នោតឲ្យជាងគេ។ ប្រសិនបើលោកអ្នកចង់ នោះលោកអ្នកអាចបោះឆ្នោតឲ្យបេក្ខជនបន្ថែមទៀតបានដែរ ដោយដាក់លេខរៀងចាប់ពីលេខ “2” ឡើងទៅនៅក្នុងគំនូស៤ជ្រុងទល់មុខនឹងឈ្មោះបេក្ខជនបន្ថែមទៀតទៅតាមការចូលចិត្តរបស់លោកអ្នកជាលំដាប់លំដោយ។

## ការបោះឆ្នោតសំរាប់ក្រុមប្រឹក្សានីតិបញ្ញត្តិ (សន្លឹកឆ្នោតធំ)

ពេលណាបោះឆ្នោតសំរាប់ក្រុមប្រឹក្សានីតិបញ្ញត្តិ លោកអ្នកអាចបោះឆ្នោតពីលើ ឬពីក្រោមខ្សែបន្ទាត់ក្រាសនៅពីលើសន្លឹកឆ្នោតនោះ

## ការបោះឆ្នោតពីលើខ្សែបន្ទាត់ក្រាស់

លោកអ្នកអាចបោះឆ្នោតពីលើខ្សែបន្ទាត់ក្រាស់ដោយដាក់លេខ “1” នៅក្នុងគំនូស៤ជ្រុង ពីលើក្រុមបេក្ខជនឈរឈ្មោះបោះឆ្នោតដែលលោកអ្នកពេញចិត្តនឹងបោះឲ្យ។ ប្រសិនបើលោកអ្នកចង់ នោះលោកអ្នកអាចបោះឆ្នោតឲ្យក្រុមបេក្ខជនបន្ថែមទៀតបានដែរ ដោយដាក់លេខរៀងចាប់ពីលេខ “2” ឡើងទៅ នៅក្នុងគំនូស៤ជ្រុងពីលើក្រុមបេក្ខជនបន្ថែមទៀតទៅតាមការចូលចិត្តរបស់លោកអ្នកជាលំដាប់លំដោយ។

## ការបោះឆ្នោតពីក្រោមខ្សែបន្ទាត់ក្រាស់

លោកអ្នកអាចបោះឆ្នោតពីក្រោមខ្សែបន្ទាត់ក្រាស់ ដោយដាក់លេខ “1”,“2”,“3”,“4”,“5”,“6”,“7”,“8”,“9”,“10”,“11”,“12”,“13”,“14” និង “15” នៅក្នុងគំនូស៤ជ្រុង ទល់មុខឈ្មោះបេក្ខជន១៥នាក់ជាលំដាប់លំដោយ ទៅតាមការដែលលោកអ្នកចូលចិត្តចំពោះបេក្ខជនទាំងនោះ។ ប្រសិនបើលោកអ្នកចង់ នោះលោកអ្នកអាចនឹងបោះឆ្នោតឲ្យបេក្ខជនបន្ថែមទៀតបានដែរ ដោយដាក់លេខរៀងចាប់ពីលេខ “16” ឡើងទៅនៅក្នុងគំនូស៤ជ្រុង ទល់មុខនឹងឈ្មោះបេក្ខជនបន្ថែមទៀតទៅតាមការចូលចិត្តរបស់លោកអ្នកជាលំដាប់លំដោយ។

## ប្រអប់សន្លឹកបោះឆ្នោត

នៅពេលដែលលោកអ្នកគូសលើសន្លឹកឆ្នោតរួចហើយ សូមបត់សន្លឹកឆ្នោតនោះដើម្បីកុំឲ្យគេឃើញឈ្មោះបេក្ខជនដែលលោកអ្នកបោះឲ្យ ហើយស៊កសន្លឹកឆ្នោតនោះចូលទៅក្នុងប្រអប់សន្លឹកបោះឆ្នោតដែលសមស្រប **នៅពេលដែលលោកអ្នកចាកចេញពីកន្លែងបោះឆ្នោត។**

## សារសំខាន់

សូមបត់ក្រដាសបោះឆ្នោត ដោយធ្វើយ៉ាងណាកុំឲ្យគេឃើញនូវការបោះឆ្នោតរបស់លោកអ្នក បង្ហាញសន្លឹកឆ្នោតដែលបត់រួចហើយនោះដល់មន្ត្រីបោះឆ្នោតប្រចាំកន្លែងបោះឆ្នោត ហើយដាក់ចូលទៅក្នុងប្រអប់បោះឆ្នោតដែលសមស្រប។

KHMER

## ការបោះឆ្នោតសំរាប់ពេលលោកអ្នកមិននៅក្នុងមណ្ឌលរបស់លោកអ្នក

**ប្រសិនបើជាលោកអ្នកនៅឆ្ងាយពីមណ្ឌលបោះឆ្នោតរបស់លោកអ្នកនៅចំថ្ងៃបោះឆ្នោត លោកអ្នកនៅតែអាចបោះឆ្នោតបានដដែល។** អ្វីដែលលោកអ្នកត្រូវធ្វើនោះ គឺលោកអ្នកគ្រាន់តែដើរទៅកាន់តុដែលគេដាក់អក្សរថា “**ABSENT**” (មិននៅ) ហើយនិយាយប្រាប់មន្ត្រីផ្លូវការអំពីទីកន្លែងដែលលោកអ្នករស់នៅ។ នៅពេលនោះមន្ត្រីផ្លូវការនឹងកត់ឈ្មោះ និងអាសយដ្ឋានរបស់លោកអ្នក ហើយដាក់ទៅក្នុងស្រោមសំបុត្រមួយដែលលោកអ្នកត្រូវចុះហត្ថលេខា។ បន្ទាប់មកគេនឹងឲ្យសន្លឹកឆ្នោតមកលោកអ្នក។ លោកអ្នកត្រូវបំពេញសន្លឹកឆ្នោតទាំងនោះនៅក្នុងបន្ទាប់បោះឆ្នោត រួចបត់សន្លឹកឆ្នោតនោះ ហើយប្រគល់ទៅឲ្យមន្ត្រីផ្លូវការនៅកន្លែងបោះឆ្នោត ដែលគេនឹងស៊កសន្លឹកឆ្នោតនោះចូលទៅក្នុងស្រោមសំបុត្របិទយ៉ាងជិត ហើយដាក់ចូលទៅក្នុងប្រអប់បោះឆ្នោត។

## ឥតមានឃើញឈ្មោះរបស់លោកអ្នកនៅក្នុងបញ្ជីបោះឆ្នោត

ប្រសិនបើលោកអ្នកឥតមានឃើញឈ្មោះចុះនៅក្នុងបញ្ជីបោះឆ្នោតទេ ឬត្រូវបានគេគូសចោលនៅពីលើបញ្ជីបោះឆ្នោតថាលោកអ្នកបានបោះឆ្នោតរួចហើយដោយសារការភ័ន្តច្រឡំរបស់មន្ត្រីផ្លូវការប្រចាំកន្លែងបោះឆ្នោត លោកអ្នកនៅតែមានសិទ្ធិបោះឆ្នោតដដែល ហើយលោកអ្នកអាចដាក់ពាក្យសុំយកផ្នែកការបោះឆ្នោតហៅថា Section Vote (ការបោះឆ្នោតតាមផ្នែក)។ គេនឹងប្រគល់ជូនលោកអ្នកនូវស្រោមសំបុត្រដែលមានសំបុត្របញ្ជាក់មួយដែលមន្ត្រីផ្លូវការនឹងបំពេញជូនលោកអ្នក ហើយស្នើសុំលោកអ្នកឲ្យចុះហត្ថលេខាពីលើសំបុត្របញ្ជាក់នោះ។ បន្ទាប់ពីលោកអ្នកបានបំពេញរួចហើយ សូមប្រគល់សន្លឹកឆ្នោតនោះទៅឲ្យមន្ត្រីផ្លូវការវិញ។ មន្ត្រីផ្លូវការនឹងស៊កសន្លឹកឆ្នោតដែលបត់រួចហើយនោះ ចូលទៅក្នុងស្រោមសំបុត្របិតយ៉ាងជិត ហើយដាក់ចូលទៅក្នុងប្រអប់បោះឆ្នោត។

## ការបោះឆ្នោតចាត់ទុកជាការសម្ងាត់

គ្មានអ្នកណាម្នាក់មានសិទ្ធិនឹងដឹងថាតើលោកអ្នកបានបោះឆ្នោតដូចម្តេចទេ។ អ្នកបោះឆ្នោតខ្លះមានការខ្វល់ខ្វាយ ដោយគិតថាការដាក់សន្លឹកឆ្នោតទៅក្នុងស្រោមសំបុត្រមួយដែលខ្លួនបានចុះហត្ថលេខា អាចនឹងនាំឲ្យជនដទៃទៀតសម្គាល់ដឹងអំពីការបោះឆ្នោតរបស់ខ្លួន។

មានតែមន្ត្រីផ្លូវការចាត់ចែងការបោះឆ្នោត ឬមន្ត្រីផ្លូវការដែលគេបានចាត់តាំង ហើយនៅចំពោះមុខអ្នកឃ្លាំមើលពិនិត្យពិច័យប៉ុណ្ណោះដែលអាចបើកស្រោមសំបុត្រសន្លឹកឆ្នោតនេះភ្លាម ទៅក្នុងប្រអប់បោះឆ្នោតមួយ។

## ជំនួយពិសេស

ជនណាដែលពុំចេះសរសេរ ឬក៏ពុំចេះមើលសេចក្តីណែនាំ ឬជនណាដែលមានពិការភាព នោះគេអាចលែលករកមិត្តភ័ក្រ ឬញាតិសន្តានណាម្នាក់ឲ្យជួយខ្លួនដើម្បីបោះឆ្នោត។ ជនទាំងនោះក៏អាចស្នើសុំមន្ត្រីផ្លូវការប្រចាំកន្លែងបោះឆ្នោតឲ្យជួយខ្លួនបានផងដែរ។

## សន្លឹកឆ្នោតដែលខូច

ប្រសិនបើសន្លឹកឆ្នោតរបស់លោកអ្នកត្រូវខូចដោយសារការគូសភ័ន្តច្រឡំ ឬដោយអចេតនាសូមកុំហែក ឬបោះចោលវា។ សូមយកសន្លឹកឆ្នោតនេះទៅឲ្យមន្ត្រីផ្លូវការប្រចាំកន្លែងបោះឆ្នោតវិញ ដើម្បីប្តូរយកសន្លឹកឆ្នោតថ្មីមួយទៀត។

KHMER